**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសុខាភិបាល**

## សេចក្តីជូនព័ត៌មានរបស់ក្រសួងសុខាភិបាល
## ស្តីពី
## ករណីព្យាបាលជាសះស្បើយ ០១នាក់ និងរកឃើញវិជ្ជមានកូវីដ១៩ ថ្មី ០៤នាក់

ក្រសួងសុខាភិបាល សូមគោរពជម្រាបជូនសាធារណជនទាំងអស់ឲ្យបានជ្រាបពីស្ថានភាពជំងឺកូវីដ១៩ នៅកម្ពុជា មានដូចខាងក្រោមនេះ៖

**១. ស្ថានភាពជំងឺកូវីដ ១៩ នៅទូទាំងប្រទេស៖**

គ្រឹមម៉ោង០៧:០០ព្រឹក ថ្ងៃទី០៣ ខែមេសា ឆ្នាំ២០២០ ស្ថានភាពជំងឺកូវីដ១៩ នៅកម្ពុជា មាន៖

– **អ្នកព្យាបាលជាសះស្បើយ** សរុបចំនួនកើនដល់ ៣៥នាក់ (ស្មើនឹង ៣០,៧០% ធៀបនឹងចំនួនអ្នកមានវីរុសកូវីដ១៩ទាំងអស់) ដែលមានបុរសជនជាតិចិន ០១នាក់ ស្ត្រីជនជាតិអង់គ្លេស ០២នាក់ បុរសជនជាតិអង់គ្លេស ០១នាក់ បុរសជនជាតិប៊ែលហ្សិក ០១នាក់ បុរសជនជាតិបារាំង ០៤នាក់ (ក្នុងនេះ មានទារកអាយុ ០៤ខែ ០១នាក់) ស្ត្រីជនជាតិបារាំង ០៥នាក់ និងបុរសជនជាតិខ្មែរ ២១នាក់ (គិតចាប់ពីខែមករាដល់បច្ចុប្បន្ននេះ)

– **អ្នកដែលកំពុងសម្រាកព្យាបាល** បានថយចុះមកនៅសរុបចំនួន ៧៩នាក់ (ស្ត្រី ២៥នាក់ និងបុរស ៥៤នាក់) នៅតាមមន្ទីរពេទ្យរដ្ឋនៅថ្នាក់ជាតិ និងថ្នាក់ខេត្ត

– **អ្នកមានវីរុសកូវីដ១៩ ដែលបានរកឃើញទាំងអស់** (រាប់ទាំងអ្នកដែលបានព្យាបាលជាសះស្បើយ និងអ្នកដែលកំពុងព្យាបាល) នៅទូទាំងប្រទេសសរុបចំនួន ១១៤នាក់ (ស្ត្រី ៣២នាក់ និងបុរស ៨២នាក់)។

**២. ករណីជាសះស្បើយ៖** មាន ០១នាក់

ទារកប្រុសអាយុ ០៤ខែ ជាកូនបង្កើតរបស់បុរសជនជាតិបារាំងដែលទើបបានព្យាបាលជាសះស្បើយដែរ ត្រូវបានឲ្យចេញពីមន្ទីរពេទ្យកុមារជាតិ។

**៣. ករណី វិជ្ជមានវីរុសកូវីដ ១៩ ថ្មី** នៅថ្ងៃទី០២ ខែមេសា ឆ្នាំ២០២០ មានចំនួន ០៤នាក់ ៖

ក. បុរសជនជាតិបារាំងអាយុ ៦៧ឆ្នាំ និងស្ត្រីជនជាតិបារាំងអាយុ ៦៧ឆ្នាំ វិជ្ជមានវីរុសកូវីដ១៩ ត្រូវបានដាក់ឲ្យនៅព្យាបាលក្នុងសណ្ឋាគារក្នុងក្រុងព្រះសីហនុ។ បុគ្គលទាំងពីររូបនេះ ជាអ្នកទេសចរបារាំងនៅក្នុងក្រុមជាមួយអ្នកទេសចរបារាំងជាង ៣០នាក់ ដែលមួយចំនួនធំបានរកឃើញមានវីរុសកូវីដ១៩ក្នុងពេលកន្លងទៅនេះ។



ទីស្តីការក្រសួងសុខាភិបាល ដីឡូត៍លេខ ៨០ វិថីសម្តេចប៉ែន នុត (២៨៩) ភ្នំពេញ ទូរស័ព្ទ-ទូរសារ: (៨៥៥-២៣) [illegible] ៩០៩

ខ. ស្ត្រីអាយុ ៥៩ឆ្នាំ ជនជាតិបារាំង វិជ្ជមានវីរុសកូវីដ១៩ ជាអ្នកនៅក្នុងចំណោមក្រុមទេសចរបារាំងចំនួន ០៨នាក់ផ្សេងពីក្រុមខាងលើ ដែលបានរកឃើញក្នុងក្រុមនេះ មានវិជ្ជមានវីរុសកូវីដ១៩ ចំនួន ០២នាក់ ដំបូងគេ) ត្រូវបានដាក់ឲ្យព្យាបាលនៅសណ្ឋាគារក្នុងក្រុងព្រះសីហនុ។

គ. បុរសអាយុ ៤០ឆ្នាំ ជនជាតិម៉ាឡេស៊ី វិជ្ជមានវីរុសកូវីដ១៩ ជាអ្នកដំណើរស្នាក់នៅបណ្តោះអាសន្ននៅឃុំពាមជីកង ស្រុកកងមាស ខេត្តកំពង់ចាម ត្រូវបានដាក់ឲ្យព្យាបាលនៅមន្ទីរពេទ្យខេត្តកំពង់ចាម។ បុរសរូបនេះ ជាក្រុមមកធ្វើការងារសាសនាមានគ្នាចំនួន ០៨នាក់ ដែលចំនួន ០៧នាក់លើកមុន បានរកឃើញមានវីរុសកូវីដ១៩ នៅស្រុកកងមាសនេះដែរ។

ក្រុមការងាររបស់ក្រសួងសុខាភិបាល កំពុងតែធ្វើកិច្ចការស្រាវជ្រាវករណីថ្មីជាបន្តទៀត ហើយនឹងបន្តជម្រាបជូនដល់បងប្អូនសាធារណជន ប្រសិនបើមានរកឃើញករណីវិជ្ជមានវីរុសកូវីដ១៩ ថ្មីណាផ្សេងទៀត។

ក្រសួងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជាទីបំផុត ជូនដល់ថ្នាក់ដឹកនាំ មន្ត្រី-បុគ្គលិកសុខាភិបាល និងក្រុមគ្រូពេទ្យទាំងអស់នៅទូទាំងប្រទេស ស្ថាប័ន និងអាជ្ញាធរពាក់ព័ន្ធទាំងអស់ ទាំងថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ អង្គការសុខភាពពិភពលោក មជ្ឈមណ្ឌលប្រយុទ្ធនឹងជំងឺឆ្លងសហរដ្ឋអាមេរិក និងវិទ្យាស្ថានប៉ាស្ទ័រកម្ពុជា ដែលបានខិតខំបំពេញភារកិច្ចបានល្អប្រសើរបំផុត ក្នុងការជួយពិនិត្យសុខភាព និងស្រាវជ្រាវរកករណីកូវីដ១៩ ព្រមទាំងអ្នកប៉ះពាល់ទាំងអស់កន្លងមក រួមទាំងការដាក់វិធានការនានា ដើម្បីទប់ស្កាត់ការចម្លងវីរុសកូវីដ១៩ នៅក្នុងប្រទេសកម្ពុជា។

ក្រសួងសុខាភិបាល បន្តជូនដំណឹងដល់សាធារណជនអំពីការវិវត្តន៍នៃបញ្ហាសុខភាព តាមទំព័រហ្វេសប៊ុក និងគេហទំព័ររបស់ក្រសួង www.cdcmoh.gov.kh ដែលគេហទំព័រនេះមានសម្ភារៈអប់រំសុខភាពដែលអាចទាញយកមកប្រើប្រាស់បាន។ សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងមកទូរស័ព្ទទាន់ហេតុការណ៍ ក្រសួងសុខាភិបាល លេខ ១១៥ ដោយឥតគិតថ្លៃ ឬទំនាក់ទំនងក្រសួងសុខាភិបាល តាមលេខទូរស័ព្ទ៖ ០១២ ៨២៥ ៤២៤ ឬ ០១២ ៤៨៨ ៩៨១ ឬ ០១២ ៨៣៦ ៨៦៨ ។

ថ្ងៃសុក្រ ១១កើត ខែចេត្រ ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០៣ ខែមេសា ឆ្នាំ២០២០



ទីស្តីការក្រសួងសុខាភិបាល ដីឡូត៍លេខ ៨០ វិថីសម្តេចប៉ែន នុត (២៨៩) ភ្នំពេញ ទូរស័ព្ទ-ទូរសារ: (៨៥៥-២៣) ៨៨៥ ៩៧០ / ៨៨៤ ៩០៩